WWF for a living planet®

**WWF កម្ពុជា**

ផ្ទះលេខ ២១ ផ្លូវលេខ ៣២២
សង្កាត់បឹងកេងកង១ ភ្នំពេញ
ប្រអប់សំបុត្រលេខ ២៤៦៧

ទូរស័ព្ទ៖ +៨៥៥ ២៣ ២១៨ ០៣៤
ទូរសារ៖ +៨៥៥ ២៣ ២១១ ៩០៩

www.cambodia.panda.org
www.panda.org/greatermekong
wwfcambodia@wwfgreatermekong.org

| **សេចក្តីប្រកាសសារព័ត៌មាន** | **សម្រាប់ចេញផ្សាយបន្ទាន់** |
| --- | --- |

# ការវាយតម្លៃហេតុប៉ះពាល់គ្មានស្តង់ដានៃគម្រោងទំនប់វារីអគ្គិសនីគំរាមកំហែងដល់ជោគវាសនានៃទន្លេមេគង្គ

**ភ្នំពេញ កម្ពុជា** – របាយការណ៍វិភាគថ្មីមួយរបស់អង្គការ WWF បានបង្ហាញថា ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់ទំនប់វារីអគ្គិសនី ដនសាហុង បានធ្វើឡើងដោយផ្អែកលើការសិក្សាដែលមិនគ្រប់ជ្រុងជ្រោយ និងខ្វះលក្ខណៈស្តង់ដា ហើយថា ប្រសិនបើគេឈរលើការវាយតម្លៃខ្សោយបែបនេះជាមូលដ្ឋានដើម្បីសាងសង់ទំនប់នេះ ធនធានជលផលនៃទន្លេមេគង្គ និងប្រជាជនចំនួន ៦០ លាននាក់ ដែលកំពុងរស់នៅក្នុងតំបន់នៃអាងទន្លេមេគង្គខាងក្រោម នឹងប្រឈមមុខនឹងហានិភ័យធ្ងន់ធ្ងរ។

ទំនប់វារីអគ្គិសនី ដន សាហុង មានទីតាំងស្ថិតនៅចម្ងាយត្រឹមតែ ១ គីឡូម៉ែត្រប៉ុណ្ណោះ ខាងលើព្រំប្រទល់កម្ពុជា ឡាវ នៅលើដងទន្លេមេគង្គ។ ប្រសិនបើសាងសង់ ទំនប់នេះនឹងបិទច្រកទឹក ហ៊ូសាហុង ដែលជាច្រកតែមួយគត់សម្រាប់ សម្រួលចរាចរត្រីសម្រាប់ពេញមួយឆ្នាំ។ ការនេះជាកត្តាបង្កឲ្យមានការខូចខាតជាអចិន្ត្រៃយ៍ដល់ធនធានជលផលដ៏សម្បូរនៅក្នុងអាងទន្លេមេគង្គ ដែលមានតម្លៃ ចន្លោះពី ១ពាន់ ៩រយ លាន ដុល្លារ ទៅដល់ ៣ពាន់ ៩រយ លាន ដុល្លារ ក្នុងមួយឆ្នាំ។

របាយការណ៍វិភាគរបស់អង្គការ WWF ដែលធ្វើឡើងដោយអ្នកជំនាញអន្តរជាតិផ្នែកផ្លូវចរាចរត្រី បានរកឃើញបញ្ហាមួយចំនួននៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលមានដូចជា វិធីសាស្ត្រស្រាវជ្រាវមិនសមស្រប កង្វះភ័ស្តុតាង ភ័ស្តុតាងដែលមានលក្ខណៈមិនច្បាស់លាស់ ព្រមទាំងការផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងការកាត់បន្ថយហេតុប៉ះពាល់ ដែលគ្មានអំណះអំណាងបញ្ជាក់អំពីប្រសិទ្ធិភាព។ បញ្ហាចំបងៗ មានដូចជាកំហុសព័ត៌មាន ស្តីអំពី ទីតាំងភូមិសាស្ត្រនៃទំនប់ អេកូឡូស៊ី និងសហគមន៍ដែលរស់នៅជុំវិញតំបន់ ដែលទាំងនេះបានបង្ហាញឲ្យឃើញច្បាស់អំពីកង្វះខាតព័ត៌មាន និងការយល់ដឹងអំពីតំបន់ និងបរិបទនៃតំបន់នោះ បើទោះបីជាគេបានសិក្សារួចហើយក៏ដោយ។

លោក **ឈិត សំអាត** នាយកអង្គការ WWF កម្ពុជាមានប្រសាសន៍ថា ៖ "ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមរបស់ទំនប់វារីអគ្គិសនី ដន សាហុង ត្រូវតែធ្វើឡើងដោយតម្លាភាព និងដោយឈរលើមូលដ្ឋានវិទ្យាសាស្ត្រច្បាស់លាស់ គឺវាមានសារៈសំខាន់ណាស់ដើម្បីធានាឲ្យមានការសិក្សា និងពិចារណាដោយល្អិតល្អន់អំពីហានិភ័យនានាដែលគំរាមកំហែងដល់ប្រជាជន ធនធានធម្មជាតិ និងសត្វព្រៃរស់នៅក្នុងតំបន់នៃអាងទន្លេមេគង្គខាងក្រោម។ ទាំងនេះហើយ ជាទិដ្ឋភាពសំខាន់ៗដែលគេត្រូវដាក់បញ្ចូលក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃទំនប់ ដនសាហុងមិនបានដាក់បញ្ចូលសម្រាប់ការសិក្សាអំពីក្តីបារម្ភពាក់ព័ន្ធនឹងតំបន់អន្តរព្រំប្រទល់ មិនបានបង្ហាញនូវទិន្នន័យចាំបាច់ក៏ដូចជាមានកង្វះខាតនូវព័ត៌មានសំខាន់ៗមួយចំនួន ដែលទាក់ទងទៅនឹងហេតុប៉ះពាល់នៃទំនប់វារីអគ្គិសនី ហេតុដូច្នេះហើយគេមិនអាចទទួលស្គាល់ការវាយតម្លៃនេះ ថាជា ការសិក្សាបែបវិទ្យាសាស្ត្របានទេ។"

គោលការណ៍ណែនាំបឋមរបស់គណៈកម្មាធិការទន្លេមេគង្គ ពាក់ព័ន្ធនឹងការស្នើគម្រោងទំនប់វារីអគ្គិសនី នៅក្នុងអាងទន្លេមេគង្គខាងក្រោម បានចែងថា គម្រោងត្រូវធានាថា ៩៥ ភាគរយ នៃប្រភេទត្រីទាំងអស់ អាចធ្វើចរាចរឆ្លងកាត់តាមផ្លូវត្រីនៃទំនប់នេះ។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមិនបានបង្ហាញនូវភស្តុតាងណាមួយ ដែលបញ្ជាក់ថាទំនប់នេះអាចបំពេញនូវ

WWF for a living planet®

ល័ក្ខខ័ណ្ឌនេះបានទេ។ ទោះបីជានៅក្នុងកាលៈទេសៈកម្រមួយ ដែលចរាចរត្រីមានការថយចុះច្រើនបំផុតត្រឹមតែ ៥ ភាគរយ ក៏ចំនួននេះនៅតែជាការបាត់បង់នូវផលប្រយោជន៍សេដ្ឋកិច្ចប្រចាំឆ្នាំដ៏ធំធេងចំពោះបណ្តាប្រទេសនៃអាងទន្លេមេគង្គ ដែលកំពុងទទួលប្រយោជន៍ពីធនធានជលផលទឹកសាបដ៏សម្បូរបែបនេះ។

លោក **ឈិត សំអាត** បានបន្តថា ៖ "ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបាននិយាយថាទំនប់ ដន សាហុង នឹងមិនប៉ះពាល់ធ្ងន់ធ្ងរដល់ធនធានជលផលឡើយ ក៏ប៉ុន្តែវាមិនបានបង្ហាញភស្តុតាងវិទ្យាសាស្រ្តណាមួយដើម្បីបញ្ជាក់អំពីការអះអាងនេះឡើយ។ ជាវិធានការមួយដើម្បីសម្រួលចរាចរត្រីឆ្លងកាត់តាមទំនប់ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បានស្នើការប្រើប្រាស់ប្រព័ន្ធជណ្តើរយន្តសំរាប់ចាប់ត្រីប្រភេទមាឌធំ ហើយដឹកជញ្ជូនពួកវាពីខាងក្រោមទំនប់ទៅផ្នែកម្ខាងទៀតនៃទំនប់ ប៉ុន្តែមិនបានផ្តល់ការសិក្សាសមស្របដើម្បីគាំទ្រការស្នើនេះឡើយ។ បន្ថែមពីលើនេះទៀត ប្រព័ន្ធបែបនេះមិនធ្លាប់បានគេអនុវត្តពីមុនឡើយនៅតំបន់អាស៊ីអាគ្នេយ៍ ឬក៏នៅក្នុងតំបន់ទន្លេមេគង្គ ដែលជាទីជម្រកសម្រាប់ ត្រីរាជ ជាប្រភេទត្រីកំពុងទទួលរងគ្រោះថ្នាក់ជិតផុតពូជបំផុត។ ត្រីនេះអាចធំធាត់ រហូតមានប្រវែង ៣ ម៉ែត្រ និងមាន ទម្ងន់ រហូតដល់ ៣០០ គីឡូក្រាម។"

ការវាយតម្លៃផលប៉ះពាល់សង្គមសម្រាប់គម្រោងដនសាហុង មិនបានដាក់បញ្ចូលភូមិសំខាន់ៗដែលនឹងអាចទទួលរងផលប៉ះពាល់ ទៅក្នុងការសិក្សារបស់ខ្លួនទេ ដោយមិនបានដាក់ចូលក្នុងការពិចារណា ឬមិនបានពិគ្រោះយោបល់ជាមួយពួកគេឡើយ។ ផែនការក្នុងការតាមដានហេតុប៉ះពាល់ចំពោះប្រជាជន និងបរិស្ថាននៅមានភាពទន់ខ្សោយ និងមិនច្បាស់លាស់ ហើយវាប្រហែលជានឹងមិនអាចផ្តល់សញ្ញាអាសន្នទាន់ពេលវេលានៅពេលដែលបញ្ហាកើតឡើងនោះទេ។ គម្រោងទំនប់នេះមិនមានផែនការជំនួយណាមួយឡើយសម្រាប់គេយកមកប្រើប្រាស់ នៅក្នុងករណីដែលវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលគេបានស្នើទទួលបរាជ័យនោះ។

លោក Marc Goichot ប្រធានកម្មវិធីគ្រប់គ្រងនិរន្តរភាពវារីអគ្គីសនី និងអាងទន្លេនៃអង្គការ WWF ប្រចាំមហាតំបន់មេគង្គមានប្រសាសន៍ថា ៖ "ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមិនមានមូលដ្ឋានវិទ្យាសាស្រ្ត និងបានស្នើយោបល់ដែលមិនអាចទុកចិត្តបាន។ ក្រុមហ៊ុនមេហ្គាហ្វើស ក្រុមអ្នកសាងសង់ទំនប់ និងរដ្ឋាភិបាលនៃបណ្តាប្រទេសនៃដងទន្លេមេគង្គ ជាអ្នកទទួលខុសត្រូវក្នុងការធានាថា ពួកគេនឹងមិនបន្តដំណើរការគម្រោងមួយនេះ ដោយផ្អែកលើការសិក្សា ដែលគ្មានលក្ខណៈវិទ្យាសាស្រ្តបែបនេះឡើយ។ យើងសូមអំពាវនាវយ៉ាងទទូចដល់ភាគីពាក់ព័ន្ធទាំងអស់ ដែលនឹងទៅចូលរួមក្នុងកិច្ចប្រជុំ ផ្នែកបច្ចេកទេស ថ្នាក់រដ្ឋាភិបាល សម្រាប់ពិនិត្យមើលសារឡើងវិញនូវរបាយការណ៍សិក្សារបស់គម្រោង នាពេលខាងមុខឆាប់ៗនេះ ដែលរៀបចំឡើងដោយរដ្ឋាភិបាលឡាវ ឲ្យពិចារណាលើបញ្ហាទាំងអស់នេះយ៉ាងម៉ត់ចត់បំផុត។"

អង្គការ WWF សូមអំពាវនាវឲ្យផ្អាកការសាងសង់ទំនប់វារីអគ្គីសនី ដន សាហុង ដើម្បីរង់ចាំរហូតដល់មានការសិក្សា បែបវិទ្យាសាស្រ្តជាក់លាក់ ល្អិតល្អន់ និងធ្វើឡើងដោយអ្នកសិក្សាឯករាជ្យចប់សព្វគ្រប់សិន ដោយត្រូវតែដាក់បញ្ចូលជាដាច់ខាតទៅក្នុងនីតិវិធីនូវការពិគ្រោះយោបល់ប្រកបដោយតម្លាភាពជាមួយរដ្ឋាភិបាល ស្ថាប័នអង្គការមិនមែនរដ្ឋាភិបាល និងបណ្តាសហគមន៍ ដែលជាអ្នកនឹងទទួលរងផលប៉ះពាល់ចេញពីការសាងសង់ទំនប់នេះ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
លោក **ទេព អស្នារិទ្ធ** ប្រធានសារព័ត៌មាននិងកិច្ចការសាធារណៈនៃអង្គការ WWF កម្ពុជា, ទូរស័ព្ទលេខ៖ +855 23 218 034,
អ៊ីម៉ែល: asnarith.tep@wwfgreatermekong.org

ដើម្បីទាញយករបាយការណ៍សង្ខេប សូមចូលទៅកាន់៖

- របាយការណ៍វិភាគរបស់អង្គការ WWF លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃទំនប់វារីអគ្គិសនី ដន សាហុង
  http://assets.panda.org/downloads/wwf_s_scientific_review_on_don_sahong_eia_final.pdf
- សេចក្ដីសង្ខេបនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
  http://assets.panda.org/downloads/don_sahong_dam___eia_brief_final.pdf

ដើម្បីទាញយករូបថត សូមចូលទៅកាន់៖ https://photos.panda.org/gpn/external?albumId=4513

**About WWF**

WWF is one of the world's largest and most respected independent conservation organizations, with over 5 million supporters and a global network active in over 100 countries. WWF's mission is to stop the degradation of the earth's natural environment and to build a future in which humans live in harmony with nature, by conserving the world's biological diversity, ensuring that the use of renewable natural resources is sustainable, and promoting the reduction of pollution and wasteful consumption.